# សេចក្តីប្រកាសព័ត៌មាន

## ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់មណ្ឌលសិក្សាចំនួន ២ ទីតាំង
## កម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត

**កម្មវត្ថុ៖** ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវមណ្ឌលសិក្សាចំនួន២ នៃកម្មវិធីអប់រំសមមូលកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត (ប៊ីប)

**គណៈអធិបតី៖**

- ឯកឧត្តមបណ្ឌិត **ពេជ សោភ័ន** រដ្ឋលេខាធិការប្រចាំការ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ឯកឧត្តម **សិរី ជំនះ** អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា
- តំណាងអង្គការយូណេស្កូនៅកម្ពុជា
- ក្រុមការងារផ្តួចផ្តើមកម្មវិធីរបស់អង្គការសហប្រជាជាតិស្តីពីការងារយុវជន អង្គការអប់រំពិភពលោក និង អង្គការក្រៅរដ្ឋាភិបាលដែលផ្តោតលើយុវវ័យ

**កាលបរិច្ឆេទ៖** ថ្ងៃព្រហស្បត្តិ៍ ទី១១ ខែកក្កដា ឆ្នាំ **២០១៩** ចាប់ពីម៉ោង **៨:០០ ព្រឹក** ដល់ម៉ោង **១២:០០**
**ទីកន្លែង៖ វិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ (NPIA)**

---

មិត្តអ្នកសារព័ត៌មានជាទីមេត្រី,

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា និង ការិយាល័យអង្គការយូណេស្កូភ្នំពេញ មានសេចក្តីសោមនស្សរីករាយក្នុងការប្រកាសពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវមណ្ឌលសិក្សានៃកម្មវិធីអប់រំសមមូលកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត (ប៊ីប) ២ កន្លែងបន្ថែមទៀតនៅក្នុងខេត្តសៀមរាប៖

១. វិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ (NPIA)
២. វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនសៀមរាប

ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃព្រហស្បតិ៍ ទី១១ ខែកក្កដា ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ (NPIA)។

កម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត គឺជាការផ្តួចផ្តើមរួមគ្នារវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា និង អង្គការយូណេស្កូ ដើម្បីផ្តល់នូវការអប់រំដែលមានភាពបត់បែន ដល់យុវជនដែលបានបោះបង់ការសិក្សា ដើម្បីឲ្យពួកគេបញ្ចប់ការសិក្សាថ្នាក់មូលដ្ឋាន ដែលមានតម្លៃស្មើនឹងថ្នាក់ទី៩។ ប៊ីប នឹងជួយយុវជនកម្ពុជាឱ្យបន្តការសិក្សារបស់ពួកគេ ស្របពេលកំពុងបំពេញការងារផ្ទាល់ខ្លួន។ ការទទួលបាននូវការអប់រំមូលដ្ឋាន នឹងជួយឱ្យពួកគេមានចំណេះដឹង និងជំនាញ ដើម្បីធ្វើឲ្យប្រសើរឡើងនូវផលិតភាព និងបំនិនជីវិត។

បន្ទាប់ពីមជ្ឈមណ្ឌលសិក្សាទី១ នៅភ្នំពេញត្រូវបានដាក់សម្ពោធឲ្យប្រើប្រាស់ជាផ្លូវការនៅខែកុម្ភៈកន្លងទៅនេះ មានសិស្សចំនួន ១៥៥៣ នាក់ដែលមកពីទីកន្លែងនានានៃប្រទេសកម្ពុជាបានចុះឈ្មោះសិក្សាតាមប្រព័ន្ធអនឡាញ(សិស្សស្រី ២៨%) និងសិស្សដែលកំពុងសិក្សាមានចំនួន១៤៨នាក់(ស្រី៤១%)។ ប៊ីប បានបង្កើតនូវកិច្ចសន្ទនាប្រកបដោយភាពរស់រវើកអំពីសារៈសំខាន់នៃការបន្តការសិក្សា និងការអប់រំពេញមួយជីវិតនៅកម្ពុជា ក្នុងចំណោមអ្នកបង្កើតគោលនយោបាយ និយោជក ដៃគូអភិវឌ្ឍន៍ និងយុវជន។

ដោយមានការគាំទ្រពីក្រុមការងារផ្តួចផ្តើមកម្មវិធីរបស់អង្គការសហប្រជាជាតិ ស្តីពីការងារយុវជននៅកម្ពុជា វគ្គសិក្សាប៊ីបនឹងត្រូវបានដាក់បញ្ចូលនៅលើបណ្តាញនៃកម្មវិធី Moodle ជាភាសាខ្មែរ ដែលមានការសហការរវាង ប៊ីប និង មជ្ឈមណ្ឌល EdTech នៃអង្គការអប់រំពិភពលោក ក្នុងនោះមានវគ្គសិក្សាអេឡិចត្រូនិចចំនួន ១១ មុខ សម្រាប់សិស្សជ្រើសរើសសិក្សា។ ប៊ីប នឹងត្រូវបានដាក់ឲ្យដំណើរការសាកល្បងនៅក្នុង ១០ មណ្ឌលសិក្សា (៥ នៅរាជធានីភ្នំពេញនិង ៥ នៅខេត្តសៀមរាប) ។ សិស្សដែលបានចុះឈ្មោះ នឹងត្រូវបានផ្តល់ជូននូវសេវាអ៊ីនធឺណិតដោយ Smart Axiata ដោយឥតគិតថ្លៃសម្រាប់ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច ស្របតាមតម្រូវការរបស់ពួកគេ។ សិស្សដែលបានបញ្ចប់មុខវិជ្ជាទាំងអស់ដោយជោគជ័យ នឹងឆ្លងកាត់ការវាស់ស្ទង់សមត្ថភាពតាមរយៈការប្រឡង និងទទួលបានវិញ្ញាបនបត្រអប់រំមូលដ្ឋាន ហើយមានឱកាសបន្តការសិក្សារបស់គេទាំងនៅវិទ្យាល័យវិជ្ជាជីវៈ ឬក៏នៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

ឯកឧត្តមបណ្ឌិត **ពេជ សោភ័ន** រដ្ឋលេខាធិការប្រចាំការ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងធ្វើជាអធិបតីនៃពិធីនេះ ដោយមានវត្តមានមន្ត្រីជាន់ខ្ពស់មកពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តំណាងក្រសួងអប់រំ យុវជន និងកីឡា អង្គការយូណេស្កូ ព្រមទាំងដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាលដែលធ្វើការក្នុងវិស័យអភិវឌ្ឍយុវជនផងដែរ។ ភ្ញៀវកិត្តិយសទាំងអស់នឹងត្រូវបានអញ្ជើញចូលរួមក្នុងការទស្សនានូវមជ្ឈមណ្ឌលសិក្សាប៊ីបផងដែរ។

***សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង:***

អ្នកស្រី ឡុង សុផាន, នាយកដ្ឋានបណ្តុះបណ្តាល longsophan@gmail.com, 092 676 776
លោក លៀវ គឹមឡាយ, មន្ត្រីកម្មវិធីអប់រំ អង្គការយូណេស្កូ, k.leav@unesco.org, 069 891 234